# របាំស្នា

ចំណុចចាប់ផ្តើមនៃរបាំស្នា មិនត្រឹមតែឈ្មោះឧបករណ៍របាំ «ស្នា» ប៉ុណ្ណោះទេ តែថែមទាំងគំនិតដែលផ្តល់ជាគន្លឹះនិងចំណាងជើងនៃរបាំស្នានេះផងដែរ។ របាំស្នាបង្ហាញអំពីការបង្កើតឡើងវិញនូវប្រវត្តិនៃចម្បាំងខ្មែរ ក្នុងស្មារតីប្រយុទ្ធការពារមាតុភូមិតទល់នឹងសត្រូវ។ ក្នុងន័យនេះ របាំស្នា មានទ្រង់ទ្រាយជារបាំបែបសង្គ្រាមដែលសិល្បករ សិល្បការិនី មានប្រើអាវុធបុរាណ គឺស្នាជាឧបករណ៍សំខាន់នៃរបាំ។

វង់តន្ត្រីកំដរដោយឧបករណ៍តន្ត្រីចម្រុះ ទាំងតន្ត្រី ចង្វាក់ និងស្គរ យកមកពីវង់តន្ត្រីយីកេ។ ចំណែកឯពាក្យពេចន៍នៃចម្រៀងបច្ចុប្បន្ន ត្រូវបានគេបង្កើតថ្មីទៅតាមព្រឹត្តិការណ៍ដែលពាក់ព័ន្ធនឹងបច្ចុប្បន្នភាពប្រទេសជាតិនាពេលនោះ។ អត្ថន័យនៃចម្រៀងខ្លះ នៅក្នុងរបាំខ្មែរពាក់ព័ន្ធនឹងមនុស្សនិងធម្មជាតិ ខ្លះទៀតពាក់ព័ន្ធនឹងនយោបាយប្រទេសជាតិ។ ចំណែកឯពាក្យពេចន៍ចម្រៀងនៃរបាំស្នា គឺរំឭកនិងបង្ហាញអំពីអតីតភាពនិងឧត្តមភាពនៃអតីតចក្រភពមហានគរខ្មែរ។

ជាស្នាដៃបង្កើតឡើងដោយសិល្បករនិងសិល្បការិនី នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រ សិល្បៈ នាសម័យមុនឆ្នាំ១៩៧៥ គេប្រើភ្លេងនិងចម្រៀងបួនបទដើម្បីកំដររបាំស្នាគឺៈ បទពោទ៍ បទសាធុការយីកេ បទឆាំឆើយ និងបទចុងឃឹម កំដរដោយវង់តន្ត្រីចម្រុះឧបករណ៍។

KHMER CIVILIZATION

<u>បទសាធុការយីកេ</u>

១. កូនខ្មែរពូកែចំណាន កូនខ្មែរក្លាហាន ការពារខេមរា (ស្ងួន)
កំទេចសត្រូវលុកលុយរដ្ឋា ស្ងួយដែនកម្ពុជា ឲ្យបានថ្កើងថ្កាន។
២. ខ្មែរស្គាល់លទ្ធផលសក្តិសិទ្ធ សត្រូវធ្លាយជិតឃោរឃៅសាមាន្យ (ស្ងួន)
បាក់បបខ្វបខ្វាចអំណាចមិនហ៊ាន ចូលមកបៀតបៀន ខ្លាចខ្មែរប្រហារ។

អត្ថបទដោយៈ បណ្ឌិត សំ សំអាង

បទធាំធើយ

បន្ទរ. កូនខ្មែរទាំងអស់គ្នា ដល់ពេលវេលា យើងក្រោកឡើងហើយ (ស្ទួន)
កម្ចាត់ពួកខ្មាំងអើយនៅបង្កើយ វាស្រែកដង្ហោយ ហៅរកយើង។

១. ជាតិខ្មែរដីខ្មែរកូនខ្មែរនៅ មិនឲ្យសត្រូវ ណាឈ្លានពាន (ស្ទួន)
ខ្មែររួមសាមគ្គី ទឹកចិត្តក្លាហាន ប្រុងប្រៀបគ្រប់ប្រាណ មិនឲ្យលិចលង់។

បន្ទរ. កូនខ្មែរទាំងអស់គ្នា ដល់ពេលវេលា យើងក្រោកឡើងហើយ (ស្ទួន)
កម្ចាត់ពួកខ្មាំងអើយនៅបង្កើយ វាស្រែកដង្ហោយ ហៅរកយើង។

២. សត្រូវឆ្វេងស្តាំខ្មែរចាំជាក់ ខ្មែរមិនមែនខ្លាក់ ខ្មែរមិនមែនល្ងង់ (ស្ទួន)
ខ្មែរស្រឡាញ់ជាតិ ស្មារតីផ្ចិតផ្ចង់ សត្រូវប៉ុនប៉ង ខ្មែរតាមប្រហារ។

បន្ទរ. កូនខ្មែរទាំងអស់គ្នា ដល់ពេលវេលា យើងក្រោកឡើងហើយ (ស្ទួន)
កម្ចាត់ពួកខ្មាំងអើយនៅបង្កើយ វាស្រែកដង្ហោយ ហៅរកយើង។

៣. ការពារបុរាណភាពទឹកដី អព្យាក្រឹត្យប្រពៃ ព្រះពុទ្ធសាសនា (ស្ទួន)
កេរ្តិ៍ខ្មែររុងរឿង ថ្កុំថ្កើងចេស្តា ពលរដ្ឋកម្ពុជា យើងបានសុខសាន្ត។

បន្ទរ. កូនខ្មែរទាំងអស់គ្នា ដល់ពេលវេលាយើងក្រោកឡើងហើយ (ស្ទួន)
កម្ចាត់ពួកខ្មាំងអើយនៅបង្កើយ វាស្រែកដង្ហោយ ហៅរកយើង។

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង






អត្ថបទដោយ៖ បណ្ឌិត សំ សំអាង





# ឯកសារពិគ្រោះ

Sam, Chan Moly, Nguon, Sam Ath, and Sam, Sam-Ang. (1988). *Khmer Folk Dance* (2nd ed.). Washington, DC: Cambodian Network Council.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង